ISSUE #102

លោកដេរេក ព្រីនស៍៖ សេចក្តីបង្រៀនជាលិខិត

ការយល់ដឹងពីព្រះគម្ពីរ ដើម្បីផ្លាស់ប្រែជីវិតរបស់អ្នក

Free COPY



ទស្សនៈអំពីភាពអស់កល្បជានិច្ច

ការជឿទុកចិត្តលើព្រះនៅកណ្តាលព្យុះ

ហេតុអ្វីបានជារឿងអាក្រក់កើតឡើងចំពោះប្រជារាស្ត្ររបស់ព្រះ?

នេះមិនត្រឹមតែជាចំណងជើងសៀវភៅដ៏មានប្រយោជន៍មួយរបស់លោក ដេរេក ព្រីនស៍ ប៉ុណ្ណោះទេ ប៉ុន្តែវាក៏ជាប្រធានបទមួយដែលគ្រីស្ទបរិស័ទគ្រប់រូប (ក៏ដូចជាមនុស្សគ្រប់គ្នាផងដែរ) តែងតែតស៊ូជាមួយវាពេញមួយជីវិត។ ការយល់ដឹងអំពីសំណួរដ៏ពិបាកយល់នេះ គឺជាប្រធានបទនៃសំបុត្រប្រចាំខែនេះ។

ឯនគ្មានសត្តមួយលើសយ៉ូប ដារ្មកបំពើរឲ្យប្លុងទេ ដ្បិតគ្មានអ្នកណាមួយ
នៅលែនដីឲ្យដូចគាត់ឡើយ ដារ្មកដែលគ្រប់លក្ខណ៍ហើយទៀងត្រង់
ក៏កោតខ្លាចដល់ព្រះ ហើយចៀសចេញពីសេចក្តីអាក្រក់ផង។

យ៉ូប 1:8

ការបោះពុម្ពផ្សាយនូវមរតកនៃការបង្រៀនរបស់លោក ដេរេក ព្រីនស៍ លេខនេះ ត្រូវបានផ្តោតចំពោះសំណួរជាសកលមួយគឺ «ហេតុអ្វីបានជាមានរឿងអាក្រក់កើតឡើង?» ដូចដែលអ្នកអាចបានដឹង វាត្រូវបានដកស្រង់ចេញពីសៀវភៅរបស់លោក ដេរេក ព្រីនស៍ ដែលមានចំណងជើងថា «ហេតុអ្វីបានជារឿងអាក្រក់កើតឡើងចំពោះរាស្ត្ររបស់ព្រះ?» ដែលខ្លឹមសារភាគច្រើនផ្អែកលើជីវិត និងបទពិសោធន៍របស់លោកយ៉ូប។

ការមើលពីភាពអស់កល្បជានិច្ច

នៅពេលយើងសិក្សាអំពីរបៀបដែលព្រះបានប្រព្រឹត្តចំពោះលោកយ៉ូប យើងចាប់ផ្តើមយល់ថា រឿងមួយមានសារៈសំខាន់ ប៉ុន្តែ ព្រះអាចទតឃើញវាតាមរបៀបខុសពីយើងទាំងស្រុង។

ទីមួយ ព្រះឲ្យតម្លៃដល់អ្វីដែលជាខាងវិញ្ញាណលើសអ្វីដែលជាខាងរូបកាយ។ ទីពីរ ព្រះឲ្យតម្លៃដល់អ្វីដែលអស់កល្បជានិច្ច ជាងអ្វីដែលបណ្តោះអាសន្ន។ ព្រះនឹងមិនលះបង់អ្វីដែលមានតម្លៃអស់កល្បជានិច្ច ដើម្បីជាប្រយោជន៍ ដល់អ្វីដែលមានតម្លៃត្រឹមតែបណ្តោះអាសន្នឡើយ។ ព្រះតែងតែធ្វើការ ដោយមានភាពអស់កល្បជានិច្ចជាគោលដៅ។ មានតែពេលយើងចូលទៅក្នុងភាពអស់កល្បជានិច្ចប៉ុណ្ណោះ ទើបយើងអាចក្រឡេកមើលថយក្រោយ ហើយឃើញនូវអ្វីដែលព្រះបានធ្វើសម្រាប់យើង។

ព្រះបន្ទូលថា៖ "មនុស្សមានបាបទាំងនេះ ដែលធ្លាប់ជាមនុស្សបះបោរ មិនបរិសុទ្ធ និងបាត់បង់ ។ យើងនឹងសង្គ្រោះពួកគេ ញែកពួកគេជាបរិសុទ្ធ ហើយលើកពួកគេឡើង។ សម្រាប់ភាពអស់កល្បជានិច្ច ពួកគេនឹងក្លាយជាសក្ខីភាពដល់សកលលោកទាំងមូលអំពីព្រះគុណរបស់យើង" ។ ប្រសិនបើនេះគឺជាគោលដៅដែលព្រះបានកំណត់សម្រាប់យើង នោះវាមិនមែនជារឿងគួរឲ្យភ្ញាក់ផ្អើលទេ ដែលយើងត្រូវឆ្លងកាត់ការសាកល្បងខ្លះៗ។

នៅពេលយើងមើលមេរៀនពីជីវិតរបស់លោកយ៉ូប តាមទស្សនៈនៃភាពអស់កល្បជានិច្ច យើងនឹងយល់ថា ហេតុអ្វីបានជាយើងត្រូវបន្តទៅមុខ ដោយអត់ធ្មត់ និងស្មោះត្រង់ ដើម្បីសម្រេចគោលបំណងដែលព្រះមានសម្រាប់យើង។

ការទុកចិត្តលើទ្រង់

ប្រហែលជាអ្នកកំពុងឆ្លងកាត់រដូវកាលនៃការរងទុក្ខ ដូចជាលោកយ៉ូបដែរ ហើយកំពុងឆ្ងល់ថា ហេតុអ្វីបានជាការលំបាកទាំងនេះ បានកើតឡើងចំពោះអ្នក។ ដូចលោក ដេរេក ព្រីនស៍ បានលើកឡើង ដោយដកស្រង់ពីលោក ហាត់សុន ថេល័រ ប្រហែលជាចម្លើយស្ថិតនៅក្នុងពាក្យមួយគឺ ការទុកចិត្ត។

ហេតុអ្វីបានជាយើងមិនចំណាយពេលបន្តិច នៅចុងបញ្ចប់នៃសំបុត្រនេះ ដើម្បីចូលមកជិតព្រះអម្ចាស់ ហើយប្រកាសពីការទុកចិត្តទាំងស្រុងរបស់យើងលើផែនការដ៏មានអធិបតេយ្យភាពរបស់ទ្រង់?



សេចក្តីអធិស្ឋាន

ព្រះអម្ចាស់អើយ! ទូលបង្គំមិនដឹងពីមូលហេតុនៃការរងទុក្ខ ដែលទូលបង្គំ និងគ្រួសាររបស់ទូលបង្គំកំពុងជួបប្រទះនោះទេ។ ប៉ុន្តែ ដោយជំនឿ ទូលបង្គំប្រកាសថា ទូលបង្គំមិនចាំបាច់ត្រូវដឹងហេតុផលទាំងអស់នោះឡើយ។ តាមរបៀបណាមួយ និងដោយមធ្យោបាយណាមួយ ទូលបង្គំជឿថា ការទាំងនេះគឺជាផ្នែកមួយនៃការសម្រេចផែនការរបស់ទ្រង់សម្រាប់ជីវិតរបស់ទូលបង្គំ។

ព្រះអម្ចាស់អើយ! ទូលបង្គំទុកចិត្តលើទ្រង់។ នៅកណ្តាលនៃការរងទុក្ខរបស់ទូលបង្គំ សេចក្តីពិតតែមួយដែលទូលបង្គំត្រូវការ គឺការធានាថាទ្រង់គង់នៅជាមួយទូលបង្គំ ហើយថា អ្វីៗទាំងអស់ដែលបានកើតឡើង មិនបានស្ថិតនៅក្រៅផែនការដ៏មានអធិបតេយ្យភាពរបស់ទ្រង់សម្រាប់ជីវិតរបស់ទូលបង្គំឡើយ។

តាមរយៈការអធិស្ឋាននេះ ទូលបង្គំសូមថ្វាយការទុកចិត្ត ជីវិត និងអនាគតរបស់ទូលបង្គំ ទៅក្នុងព្រះហស្តរបស់ទ្រង់។ នៅក្នុងព្រះនាមព្រះយេស៊ូវគ្រីស្ទ។ អាម៉ែន!

ស្វែងយល់ពីព្រះបន្ទូលព្រះឲ្យកាន់តែស៊ីជម្រៅ

សេចក្តីបង្រៀនជាលិខិតរបស់លោកដេរេក ព្រីនស៍ អាចទាញយកដោយឥតគិតថ្លៃពីគេហទំព័ររបស់យើង www.derekprince.com/km-kh/resources

ស្កេន QR ដើម្បីចូលគេហទំព័រ DPM-KH

Unless otherwise noted, all Scripture referenced in this article is the New King James Version.
Images: istockphoto (ID: 523644573; ID:1143334423) | pixabay (ELG21)
Product TL 25-5 | Wiki L165

ព័ន្ធកិច្ច ដេរេក ព្រីនស៍ កម្ពុជា
Facebook / Youtube: Derek Prince Ministries Cambodia | www.derekprince.com/km-kh

ឥឡូវនេះ យើងមិនអាចមើលឃើញអ្វីៗទាំងអស់បានទេ។ យើងត្រូវដើរដោយជំនឿ និងទុកចិត្តលើទ្រង់។

ខ្ញុំមានការចាប់អារម្មណ៍យ៉ាងខ្លាំង ចំពោះពាក្យដ៏ស្រស់ស្អាតមួយដែលលោក ហាតសុន ថៃលឺ បានសរសេរ។ គាត់ជាអ្នកផ្សព្វផ្សាយដំណឹងល្អដ៏អស្ចារ្យម្នាក់ ក្នុងសតវត្សទីដប់ប្រាំបួន ជាស្ថាបនិកនៃព័ន្ធកិច្ច China Inland Mission ហើយជាមនុស្សរបស់ព្រះ ដែលមាននិមិត្តសម្រាប់ប្រទេសចិន។ នៅជិតចុងបញ្ចប់នៃជីវិតរបស់គាត់ គាត់បានសរសេរថា៖

"កាលពីមុន ខ្ញុំធ្លាប់មានទស្សនៈច្បាស់លាស់អំពីអ្វីដែលខ្ញុំនឹងធ្វើសម្រាប់ព្រះ។ ប៉ុន្តែឥឡូវនេះ ខ្ញុំលែងមានទៀតហើយ ខ្ញុំគ្រាន់តែដើរទៅមុខដោយការទុកចិត្តប៉ុណ្ណោះ" ។

នោះហើយជាភាពចាស់ទុំខាងវិញ្ញាណ។ ភាពចាស់ទុំ មិនមែនមានន័យថា ក្លាយជាមនុស្សដែលឆ្លាតជាងមុននោះទេ។ ផ្ទុយទៅវិញ វាមានន័យថា ក្លាយជាមនុស្សដែលទុកចិត្តព្រះកាន់តែខ្លាំងឡើង។

ព្រះរីករាយនឹងភាពស្មោះត្រង់របស់យើង

យើងអាចមើលឃើញ ពីរឿងរ៉ាវរបស់លោកយ៉ូបថា ព្រះអាចមានព្រះទ័យពេញចិត្តយ៉ាងខ្លាំង ចំពោះអ្នកបម្រើដ៏ស្មោះត្រង់របស់ទ្រង់។ ខ្ញុំប្រើឃ្លានេះដោយប្រុងប្រយ័ត្ន ពីព្រោះព្រះមិនមានអំនួតឡើយ។ ប៉ុន្តែ ព្រះរីករាយ និងសព្វព្រះទ័យចំពោះមនុស្ស ដែលធ្វើតាមព្រះហឫទ័យរបស់ទ្រង់។ សូមពិចារណាម្តងទៀត នូវអ្វីដែលព្រះបានមានព្រះបន្ទូល ទៅកាន់សាតាំង នៅក្នុងគម្ពីរយ៉ូប 1:8៖

"រួចព្រះយេហូវ៉ាទ្រង់សួរសាតាំងថា ឯងបានសង្កេតមើលយ៉ូប ជាអ្នកបំរើអញឬទេ ដ្បិតគ្មានអ្នកណាមួយនៅផែនដីឲ្យដូចគាត់ឡើយ ជាអ្នកដែលគ្រប់លក្ខណ៍ ហើយទៀងត្រង់ ក៏កោតខ្លាចដល់ព្រះ ហើយចៀសចេញពីសេចក្ដីអាក្រក់ផង" ។

ព្រះសព្វព្រះទ័យនឹងលោកយ៉ូបយ៉ាងខ្លាំង រហូតដល់ទ្រង់បានលើកគាត់ឡើងនិយាយចំពោះសាតាំង។ ដូចជាព្រះកំពុងមានព្រះបន្ទូលថា៖ "សាតាំង ឯងមិនអាចមានជ័យជំនះលើគាត់ទេ គាត់នៅតែដើរតាមយើង" ។ យើងដឹងហើយថា សាតាំងបានឆ្លើយតបយ៉ាងដូចម្តេច៖ "ចូរដកយកអ្វីៗដែលគាត់មានចេញទៅ ហើយយើងនឹងឃើញថាមានអ្វីកើតឡើង ។"

ហេតុការណ៍នេះត្រូវបានកើតឡើងម្តងទៀត នៅពេលសាតាំងបង្ហាញខ្លួនជាលើកទីពីរ៖



"រួចព្រះយេហូវ៉ាទ្រង់សួរថា ឯងបានសង្កេតមើលយ៉ូប ជាអ្នកបំរើអញឬទេ ដ្បិតគ្មានអ្នកណាមួយនៅផែនដីឲ្យដូចគាត់ឡើយ ជាអ្នកដែលគ្រប់លក្ខណ៍ ហើយទៀងត្រង់ ក៏កោតខ្លាចដល់ព្រះ ហើយចៀសចេញពីសេចក្ដីអាក្រក់ផង មួយទៀត ទោះបើឯងបណ្តាលឲ្យអញទាស់នឹងគាត់ ដើម្បីនឹងបំផ្លាញចេញ ដោយឥតហេតុក៏ដោយ គង់តែគាត់នៅរក្សាលក្ខណៈខ្លួនដដែល" ។

(យ៉ូប 2:3)

តើអ្នកដឹងទេថា នៅពេលអ្នកអានអត្ថបទនេះ ព្រះអាចនឹងកំពុងចង្អុលទៅកាន់អ្នក? ប្រហែលជាទ្រង់កំពុងមានព្រះបន្ទូលទៅកាន់សាតាំងអំពីអ្នកថា៖ "សាតាំង តើអ្នកបានពិចារណាអំពីមនុស្សនោះទេ? ពួកគេស្មោះត្រង់។ ពួកគេបានឆ្លងកាត់ការលំបាក។ ពួកគេមិនដែលបោះបង់ ឬបដិសេធយើងឡើយ។ ពួកគេនៅតែស្មោះត្រង់ចំពោះការប្តេជ្ញាចិត្តដំបូងរបស់ពួកគេ។" គំនិតដែលថា ព្រះជាម្ចាស់អាចរួតអំពីយើង គឺជារឿងដ៏គួរឲ្យរំភើបណាស់!

ទស្សនៈពីស្ថានសួគ៌

កណ្ឌគម្ពីរយ៉ូប ក៏ផ្តល់ឲ្យយើងនូវទស្សនៈពីស្ថានសួគ៌ចំពោះព្រឹត្តិការណ៍ ដែលកើតឡើងនៅលើផែនដីផងដែរ ដែលនេះជាលក្ខណៈពិសេសមួយរបស់ព្រះគម្ពីរ។ នៅពេលយើងអានរឿងរ៉ាវរបស់លោកយ៉ូប យើងអាចអានវាដោយមើលឃើញនូវអ្វីដែលបានកើតឡើងនៅស្ថានសួគ៌ មុនពេលរឿងរ៉ាវនោះចាប់ផ្តើមនៅលើផែនដី។ យើងឃើញឈុតឆាកមួយ ដែលព្រះកំពុងចង្អុលបង្ហាញលោកយ៉ូបទៅកាន់សាតាំង ហើយមានព្រះបន្ទូលថា៖ "សាតាំងអើយ ឯងមិនអាចយកឈ្នះគាត់បានទេ។ គាត់នៅតែកាន់ខ្ជាប់នូវភាពសុចរិតរបស់គាត់។ យើងសព្វព្រះទ័យនឹងគាត់ណាស់" ។

អស់រយៈពេលជាច្រើនឆ្នាំមកហើយ ខ្ញុំបានអនុវត្តទម្លាប់មួយ គឺប្រកាសព្រះបន្ទូលរបស់ព្រះ ដោយបញ្ចេញសំឡេង។ ខ្ញុំបានសង្កេតឃើញថា នៅពេលខ្ញុំទទួលបានសេចក្តីប្រកាសថ្មីមួយពីព្រះ ហើយចាប់ផ្តើមប្រកាសវា ស្ទើរតែភ្លាមៗនោះ នឹងមានអ្វីមួយកើតឡើង ដើម្បីរារាំងខ្ញុំ។ អាចមានការរំខាន ឬឧបសគ្គណាមួយកើតឡើង ដែលមានគោលបំណងធ្វើឲ្យខ្ញុំបោះបង់សេចក្តីប្រកាសនោះចោល។ ឬក៏សត្រូវនឹងព្យាយាមបង្ហាញថា សេចក្តីប្រកាសនោះមិនពិត ឬព្យាយាមបញ្ចុះបញ្ចូលខ្ញុំថា ខ្ញុំមិនអាចប្រកាសវាជាសេចក្តីពិតបានឡើយ។

នៅពេលនោះ ខ្ញុំតែងតែត្រូវប្រឈមមុខនឹងការសម្រេចចិត្តមួយ៖ តើខ្ញុំនឹងបន្តប្រកាសវាទៀត ឬខ្ញុំនឹងអនុញ្ញាតឲ្យកាលៈទេសៈជាអ្នកកំណត់អ្វីដែលខ្ញុំជឿ? រាល់ពេលដែលរឿងនេះកើតឡើង ខ្ញុំចាត់ទុកវាជាសញ្ញាល្អមួយ។ ពីព្រោះសញ្ញាមួយដែលបង្ហាញប្រាប់ថា អ្វីមួយស្ថិតនៅក្នុងព្រះហឫទ័យរបស់ព្រះ គឺសាតាំងនឹងប្រឆាំងនឹងវា។ នៅពេលយើងជួបនឹងការតស៊ូ ឬការប្រឆាំងពីសត្រូវ នោះមានន័យថា យើងកំពុងធ្វើឲ្យអារក្សទទួលការខាតបង់ ហើយកំពុងរំខានដល់ផែនការរបស់វា។

ការបើកបង្ហាញដោគវាសនារបស់យើង

ព្រះមានផែនការ និងដោគវាសនាមួយសម្រាប់លោកយ៉ូប ហើយដូចគ្នានេះដែរ ព្រះក៏មានដោគវាសនាដ៏ខ្ពង់ខ្ពស់មួយសម្រាប់យើងនៅក្នុងព្រះគ្រីស្ទ។ ដោគវាសនាដែលព្រះបានរៀបចំសម្រាប់យើង គឺវាអស្ចារ្យលើសពីការស្រមៃ។ វាស្ទើរតែមិនគួរឲ្យជឿថា ព្រះបានគ្រោងទុកអ្វីសម្រាប់យើង។ សាវ័កប៉ុលបានសរសេរនៅក្នុង អេភេសូរ 2:4–6 ថា៖

"ប៉ុន្តែ ព្រះដែលទ្រង់មានសេចក្តីមេត្តាករុណាដ៏លើសលប់ ដោយព្រោះសេចក្តីស្រឡាញ់ជាខ្លាំង ដែលទ្រង់មានដល់យើងរាល់គ្នា ក្នុងកាលដែលយើងនៅស្លាប់ក្នុងការរំលងនៅឡើយ នោះទ្រង់បានប្រោសឲ្យយើងរាល់គ្នាបានរស់ ជាមួយនឹងព្រះគ្រីស្ទ គឺដោយព្រះគុណដែលអ្នករាល់គ្នាបានសង្គ្រោះ ហើយទ្រង់បានប្រោសឲ្យយើងរស់ឡើងវិញ ក៏ឲ្យយើងអង្គុយជាមួយនឹងព្រះគ្រីស្ទ នៅស្ថានដ៏ខ្ពស់ដែរ" ។

ការបកប្រែរបស់ Weymouth ប្រើពាក្យថា "បានដាក់យើងឲ្យគ្រងរាជ្យ" (enthroned us)។ យើងត្រូវបានធ្វើឲ្យមានជីវិតឡើងវិញ។ យើងត្រូវបានប្រោសឲ្យរស់ឡើងវិញ។ យើងត្រូវបានដាក់ឲ្យគ្រងរាជ្យជាមួយទ្រង់។ អ្វីៗទាំងអស់នេះ ត្រូវបាននិយាយក្នុងកាលអតីតកាល មិនមែនជារឿងដែលនឹងកើតឡើងនៅពេលអនាគតទេ។ បន្ទាប់មក សាវ័កប៉ុលបានបញ្ជាក់ពីមូលហេតុនៅក្នុងខទី៧ថា៖

"ដើម្បីឲ្យទ្រង់បានសំដែង ឲ្យអស់ទាំងកល្បខាងមុខ បានឃើញព្រះគុណដ៏ធ្ងន់លើសលប់របស់ទ្រង់ ដោយសេចក្តីសប្បុរស ដែលទ្រង់ផ្តល់មកយើង ក្នុងព្រះគ្រីស្ទយេស៊ូវ" ។

នេះគឺជាគំនិតដ៏អស្ចារ្យមួយ! ហាក់ដូចជាព្រះកំពុងមាន